# ខ្លឹមសារនិងសារៈប្រយោជន៍នៃកច្ចព្រមព្រៀងសន្តិភាព២៣តុលា

## (២៣តុលា២០១៤)

នៅឆ្នាំ ១៩៧៩ នៅពេលដែលយួនបង្ខំចិត្តចូលឈ្លានពានកម្ពុជា ព្រោះខ្លាចអន្តរជាតិចូលមកមុនហើយធ្វើអោយបែក ការនិងខូចគម្រោងការណ៍យួន ដូច្នេះយួនបានប្រញេបប្រញាប់រៀបចំការទូតមួយចំនួនសម្រាប់តវ៉ាជាមួយ សហគមន៍ អន្តរជាតិមុននឹងវាយលុកឈ្លានពានកម្ពុជា ដើម្បីបញ្ជាក់ពីភាពស្របច្បាប់នៃការឈ្លានពានរបស់យួនមកលើកម្ពុជាថា ជាការចាំបាច់និងត្រឹមត្រូវ ដោយបានរៀបចំ កុន ល្ខោន សរសេរសៀវភៅប្រវត្តិសាស្ត្រ និងជាពិសេសរៀបចំធុតធាកដ៏ គួរអោយរន្ធត់នៃពន្ធាគា ស២១ដើម្បីទម្លាក់កំហុសទាំងស្រុងលើខ្មែរក្រហមមួយក្រុមនៅពេលដែលយួន ព្យាយាមលាក់ ការពិត៩០%ទៀត ដើម្បីយកលេសថាយួនមករំដោះខ្មែរពីវាលពិឃាត។ ហេតុផលទីពីរ យួនបានយកលេសថា មកពី ខ្មែរក្រហមបានឈ្លានពានប្រទេសយួន ដោយបានវាយលុកខេត្តមួយចំនួនតាមបណ្តោយព្រំដែនខ្មែរ-យួន និងបាន សម្លាប់ប្រជាជនស៊ីវិលអស់ជាច្រើន ទើបយួនចាំបាច់វាយតបវិញព្រោះជាសិទ្ធិនៃស្វ័យការពារ។ ប៉ុន្មានថ្ងៃក្រោយមាន ការវាយប្រហារតាមបណ្តោយព្រំដែនខ្មែរ-យួន ក្រុមការទូតយួនដែលបានរៀបចំជាស្រេច បានធ្វើទំនាក់ទំនងជាមួយ សហគមន៍អន្តរជាតិ ហើយបានទទួលប្រតិភូមិនៃអង្គការសហប្រជាជាតិចុះទៅមើលដល់កន្លែងកើតហេតុ។ យួនបាន ថតនិងរៀបចំឯកសារយកទៅប្តឹងអន្តរជាតិពីការឈ្លានពានរបស់ខ្មែរក្រហមដើម្បីស្វែងរកការគាំទ្រពីអន្តរជាតិ ឬយ៉ាង ហោចណាស់សុំកុំអោយសហគមន៍អន្តរជាតិថ្កោលទោសការឬដាក់គំនាបសេដ្ឋកិច្ចលើយួន ចំពោះការឈ្លានពានរបស់ យួនមកលើកម្ពុជា តែអន្តជាតិពុំបានជឿយួនសោះឡើយ ព្រោះសហគមន៍អន្តរជាតិដឹងច្បាស់ណាស់ថា យួននៅពី ក្រោយរបបប្រល័យពូជសាសន៍ ហើយយួនបានរកលេសឈ្លានពានកម្ពុជា ព្រោះតែមានទំនាស់ជាមួយប៉ុល-ពត។

ភាគីយួនគិតស្មានថា ហេតុផលទាំងនេះអាចធ្វើអោយអន្តរជាតិមិនដាក់គំនាបឬទណ្ឌកម្មសេដ្ឋកិច្ចនិងការទូតមកលើ ប្រទេសយួនក្រោយការឈ្លានពានកម្ពុជា តែសហគមន៍អន្តរជាតិមិនទទួលស្គាល់លេសទាំងនេះទេ ហើយបានដាក់ គំនាបសេដ្ឋកិច្ចនិងការទូតលើយួនយ៉ាងធ្ងន់ធ្ងរ គឺមិនបើកទីផ្សារកស៊ីជាមួយយួន និងមិនមានទំនាក់ទំនងការ ទូតអ្វី ជាមួយយួនទាល់តែសោះ ហើយថែមទាំងរក្សាកៅអីខ្មែរនៅអង្គការសហប្រជាជាតិទៅអោយក្រុមខ្មែរក្រហម ដែលតស៊ូ ប្រឆាំងនឹងការឈ្លានពានរបស់យួន។ នេះជាបរាជ័យមួយដ៏ធ្ងន់ធ្ងររបស់យួន ព្រោះគំនាបសេដ្ឋកិច្ចនិងការទូតនេះធ្វើ អោយប្រទេសយួនដែលទើបងើបពីភ្លើងសង្គ្រាមយ៉ាងដុនដាប មិនអាចមានជង្ហើមរស់បានសោះឡើយ ហើយទោះជា យួនអាចប្លន់ភោពទ្រព្យយ៉ាងសន្ធឹកសន្ធាប់ពីប្រទេសខ្មែរនិងលាវ ក៏យួនមិនដឹងយកទៅលក់ឯណា ព្រោះគ្មានទីផ្សា។ កាលណោះយួនរហេមរហាមខ្លាំងណាស់ ហើយទោះជាយួនខំប្លន់ជំនួយមនុស្សធម៌ពីសហគមន៍អន្តរជាតិដែលគេផ្តល់ អោយខ្មែរដែលជាជនរងគ្រោះ ក៏យួននៅតែមិនអាចរស់បាន កាលណោះយួនពឹងផ្អែកទាំងស្រុងលើជំនួយពីប្លុកកុំម្មុយ នីស្ត ហើយពេលដែលសហភាពសូវៀតចុះអន់ខ្សោយមិនអាចបន្តជួយយួនអោយឈ្លានពានកម្ពុជាតទៅទៀតបាន យួនរិតតែខ្សោះខ្សល់រកកលស្លាប់តែម្តងបើគ្មានការសង្គ្រោះបន្ទាន់តាមការចរចាសន្តិភាព និងការដេកគំនាបសេដ្ឋកិច្ច និងការទូតពីសហគមន៍អន្តរជាតិ។ ផ្ទុយពីយួន ចលនាតស៊ូរបស់ខ្មែរប្រឆាំងយួននៅតាមបណ្តោយព្រំដែនខ្មែរ-ថៃបាន ទទួលការគាំទ្រយ៉ាងខ្លាំងក្លាឡើងពីសហគមន៍អន្តរជាតិនិងខ្មែរទូទាំងសកលលោក។ អាមេរិកនិងចិន រួមទាំងប្រទេស ឯទៀតក្នុងលោកបានជួយគាំទ្រការតស៊ូរបស់ខ្មែរប្រឆាំងនឹងយួនឈ្លានពាន ព្រោះគេចាត់ទុកថា ជាការតស៊ូ ប្រកបដោយភាពត្រឹមត្រូវនិងស្របច្បាប់ នៅពេលដែលប្រទេសមួយធ្វើការតស៊ូប្រឆាំងនឹងការឈ្លានពានពីប្រទេសធំ មួយទៀត ហើយក៏ជាការតស៊ូរវាងមនោគមន៍សេរីនិងកុំម្មុយនីស្ត ដូច្នេះយួនគ្មានដំណោះស្រាយអ្វីផ្សេងទៀតក្រៅពីការ សុំចរចា ដែលវាអោយឈ្មោះថា ការស្វែងរកសន្តិភាពឬនិយាយពីសន្តិភាព ព្រោះយួនត្រូវការសង្គ្រោះបន្ទាន់ពីស្ថានភាព

នេះ។ ដូច្នេះយួនវារកផ្លូវទាក់ទងបណ្តាញវា ទោះនៅក្នុងសង្គមខ្មែរ ឬលើឆាកអន្តរជាតិដើម្បីជួយ សម្រុះសម្រួលជំនួបរវាងភាគីទាំងសងខាង។ យើងឃើញចរិតយួននិងពួកកុំម្មុយនីស្តច្បាស់ណាស់ ពេលវាចាញ់ វាសុំចរចារសន្តិភាព តែបើវាឈ្នះវិញ គឺវាសម្លាប់យើងគ្មានប្រណីទេ សូម្បីកូនក្មេងបាតជើងក្រហមវងាលក៏វាមិន លើកលែងដែរ។

ក្នុងបទសម្ភាសមួយរបស់លោកស្រី ពុងឈីកេក ជាមួយវិទ្យុអាស៊ីសេរី បញ្ជាក់អោយឃើញថា លោកស្រីនេះ និងក្រុមគ្រួសារលោកស្រីនេះនិងឥស្សរៈជនបារាំងពីរបីនាក់ទៀត បានដើរតួរយ៉ាងសំខាន់ក្នុងការសម្រុះសម្រួលជំនួបរវាងភាគីយួនឬហ៊ុន-សែន ជាមួយភាគីតស៊ូខ្មែរ តំណាងដោយស៊ីហនុ។ គឺលោកស្រីនិងប្តីលោកស្រី ពុងឈីកេក រួមទាំងឥស្សរៈជនបារាំងបានជួយធ្វើអន្តរាគមន៍យ៉ាងសកម្មសម្រុះសម្រួលជំនួនរវាងភាគីយួនឬហ៊ុនសែននិងស៊ីហនុ តាំងតែពីឆ្នាំ១៩៨៣ដល់ឆ្នាំ១៩៨៨ រហូតឈានដល់ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពមួយនៅថ្ងៃទី២៣តុលា១៩៩១នៅក្រុងប៉ារីស។ ហើយដើម្បីអរគុណដល់លោកស្រីនេះ ខាងយួនឬគណបក្សប្រជាជន បានផ្តល់កិត្តិយសនិងតួនាទីសំខាន់ណាស់ដល់លោកស្រី ពុងឈីកេក និងខ្សែស្រឡាយគ្រួសារបក្សពួកលោកស្រីក្នុងសង្គមរបស់គេ។ លោកស្រីជាបងស្រីធម៌របស់ហ៊ុន-សែន ហើយលោកស្រីជាអ្នកសម្រុះសម្រួលដើម្បីអោយប្អូនជីដូនមួយខ្លួនទទួលឯកសិទ្ធក្នុងការរស៊ីលក់ដីនិងរបបរកស៊ីមួយចំនួនទៀត។ល។ ហើយតួនាទីសំខាន់មួយទៀតរបស់ លោកស្រីនិងបណ្តាញលោកស្រី គឺជួយលាក់បាំងការពារឧក្រិដ្ឋកម្មរដ្ឋអំណាចហ៊ុនសែននិងផលប្រយោជន៍ចិនយួនកលើឆាកអន្តរជាតិ។ របាយការណ៍អុនៗរបស់អង្គការលោកស្រីនិងបណ្តាញលោកស្រីបានត្រឹមជួយលាក់បាំងឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលកើតនៅកម្ពុជា...គឺមិនខុសពីយួនដែលនិយាយរឿងខ្មែរក្រហមមួយជ្រុងតូចតែលាក់ការពិត៩០%ទៀត។

នៅថ្ងៃទី ២៣តុលា១៩៩១ នៅក្រុងប៉ារីស ប្រទេសទាំងឡាយចំនួន ១៨ បានចុះហត្ថលេខាសន្យាឈប់រំលោភឈ្លានពានកម្ពុជា ហើយគោរពធិបតេយ្យបូរណភាពទឹកដីនិងសិទ្ធិនៃពលរដ្ឋខ្មែរ ហើយថែមទាំងធានាជួយអន្តរាគមន៍ជួយសង្គ្រោះកម្ពុជា បើកម្ពុជារងការឈ្លានពានណាមួយដូចបានចុះក្នុងមាត្រាទី៥នៃកិច្ចព្រមព្រៀងស្តីពីអធិបតេយ្យកម្ពុជា។ ឆ្លើយតបនឹងការសន្យានេះ សហគមន៍អន្តរជាតិបានដកគំនាបសេដ្ឋកិច្ចនិងការទូតពីយួន បានន័យថា សហគមន៍អន្តរជាតិបើកផ្លូវរកស៊ីដោយសេរីជាមួយយួន និងទទួលស្គាល់មុខមាត់យួនលើឆាកអន្តរជាតិ។ តែគួរអោយអនិច្ចារសម្រាប់ខ្មែរ ទាំងនេះវាគ្រាន់តែជាឆាកសោជនាកម្មមួយដ៏ខ្លោចផ្សា ព្រោះអ្នកតស៊ូខ្មែរដែលរំសាយពីការតស៊ូ ត្រូវបានពួកកុំម្មុយនីស្តបោកយកទៅសម្លាប់ម្តងមួយៗ ហើយមួយចំនួនត្រូវគេប្រហារក្នុងព្រឹត្តិការណ៍ដ៏យ៉ង់ឃ្នង ហើយប្រទេសចិន យួន ថៃ និងប្រទេសមួយចំនួនទៀតមានជប៉ុនឥណ្ឌា។ល។ ពុំបានគោរពការសន្យារបស់ខ្លួនទេ។ ចិនក្តី យួនក្តី និងប្រទេសមួយចំនួនទៀត បានបន្តឈ្លានពានរំលោភកម្ពុជា ប្លន់ធនធានទឹកដីនិងសេដ្ឋកិច្ចខ្មែរគ្មានសល់ ហើយពួកនេះថែមទាំងសុំគ្រលំជាន់ពន្លិចបំភ្លេចកិច្ចសន្យាដែលគេបានចុះហត្ថលេខា ហើយព្យាយាមកប់ឬសម្លាប់ចោលតែម្តងព្រោះគេខ្លាចកិច្ចសន្យានេះ។ ភាគីយួនមិនត្រឹមតែមិនបានគោរពកិច្ចសន្យានោះទេ ថែមទាំងបន្តជិះជាន់គាបសង្កត់ពលរដ្ឋខ្មែរនិងបានដាក់អាណានិគមន៍បែបថ្មីមកលើកម្ពុជា។ យួនបានទន្ទ្រានទឹកដីធនធានធម្មជាតិខ្មែរយកទៅលក់អោយពួកលោកខាងលិចក្លាយជាសេដ្ឋីគ្រប់គ្នា ហើយបន្តប្រល័យពូជសាសន៍ខ្មែរក្រោមរូបភាពផ្សេងៗ។ ទាំងនេះជាអំពើដ៏យ៉ង់ឃ្នង និងអយុត្តិធម៌ ដែលមិនអាចទទួលយកបាន ព្រោះសហគមន៍អន្តរជាតិបានដកគំនាបសេដ្ឋកិច្ច និងការទូតពីយួនដោយគ្មានលក្ខខ័ណ្ឌ គ្មានការត្រួតពិនិត្យថាតើ យួនបានបំពេញលក្ខខណ្ឌ័ដែលយួនបានសន្យាឬទេ? ហេតុអ្វីសហគមន៍អន្តរជាតិបណ្តោយអោយយួនធ្វើអ្វីតាមតែអំពើចិត្តជាង២០ឆ្នាំមកហើយ? តើនេះមិនមែនជាការសុំគ្រលំក្នុងឧក្រិដ្ឋកម្មយួនទេឬ? ទាំងនេះជាហេតុផលនៃការតវ៉ារបស់ពលរដ្ឋខ្មែរដែលចូលរួមពិធីរំលឹកខួប២៣តុលាកាលពីម្សិលមិញ គឺប្រជាពលរដ្ឋខ្មែរចង់អោយសហគមន៍អន្តរជាតិកោះប្រជុំបង្កើតគណកម្មការត្រួតពិនិត្រការអនុវត្តន៍កិច្ច

ព្រមព្រៀងសន្តិភាព ២៣ តុលា ហើយចាត់វិធានការសមស្របចំពោះជនឬប្រទេសដែលបានរំលោភកិច្ចសន្យានេះ។ ទាំងនេះជាការទទួលខុសត្រូវរបស់សហគមន៍អន្តរជាតិដែលបានបើកផ្លូវអោយមានអាណានិគមន៍បែបថ្មីមកលើកម្ពុជា និងការរំលោភសិទ្ធិសេរីភាពគ្រប់យ៉ាងមកលើពលរដ្ឋខ្មែរដោយសេរី។ ម្យ៉ាងវិញទៀត កាលដែលប្រទេសទាំងឡាយ ជាពិសេស ចិននិងយួន នាំគ្នាមករំលោភទន្រ្ទានទឹកដី សេដ្ឋកិច្ច និងធនធានធម្មជាតិ របស់ខ្មែរយ៉ាងអាណាធិបតេយ្យខ្វេចខ្ទីគ្មានសល់អ្វី ហើយមិនតែប៉ុណ្ណោះថែមទាំងឈ្លោះកាប់ចាក់គ្នាក្នុងការទន្ទ្រានេះ ដោយប្រើកម្លាំងប៉ូលីសឬយោធាឯកជនរបស់គេ ទាំងនេះគឺជាគ្រោះមហន្តរាយមួយទៀតដែលខ្មែរជាជនរងគ្រោះត្រូវប្រឈមមុខដោយជៀសមិនផុតទោះចង់ឬមិនចង់ក្តី។ ហើយប្រឈមនឹងអំពើឈ្លានពាននេះ មានតែកិច្ចព្រមព្រៀងទីក្រុងប៉ារីស ២៣តុលានិងអន្តរគមន៍របស់អន្តរជាតិដោយសន្តិវិធីទេ ដែលមាចបញ្ចៀសបញ្ហាទាំងនេះ ឬក៏បើកផ្លូវទៅរកសង្គ្រាមមួយដ៏យ៉ង់យ្ឃង ដូចកាលពីសម័យសង្គ្រាមត្រជាក់។ កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស២៣តុលាជាដំណោះស្រាយដោយសន្តិវិធីដ៏សមស្របជៀសវាងការបង្ហូរឈាមបើស្ថានការណ៍ឈានដល់ដំណាក់ការធ្ងន់ធ្ងរ ដែលមិនមែនជាការបង្គរឬចង់បានរបស់ពលរដ្ឋខ្មែរ តែនឹងបង្ករឡើងដោយពួកឈ្លានពាននិងឈ្មួញសង្គ្រាមដែលកំពុងតែប្រខាំគ្នាក្នុងការ ទន្ទ្រានទឹកដីធនធាននិងសេដ្ឋកិច្ចពលរដ្ឋខ្មែរ។ ស្ថានការណ៍ស្រុកខ្មែរអាចនឹងប្តូរផ្លាស់ តែមួយប៉ព្រេចភ្នែកដូចកាលរពីសម័យសង្គ្រាមត្រជាក់បើស្ថានភាពភូមិសាស្រ្តនយោបាយឈានដល់ដំណាក់ការណ៍តានតឹងធ្ងន់ធ្ងរ។ ថ្មីៗនាំអាមេរិកនិងបស្ចឹមប្រទេសទើបនឹងដកទណ្ឌកម្មសម្ភារុធពីយួន នេះជាការមួយគួរអោយព្រួយបារម្ភចំពោះអ្វីដែលអាចនឹងកើត មានឡើង។

រឿងសំខាន់មួយទៀតដែលខ្មែរត្រូវចងចាំអោយច្បាស់គឺ ថ្វីបើសហគមន៍អន្តរជាតិមិនបានធ្វើអន្តរគមន៍អោយទាន់ពេលវេលានៅក្នុងរបបវាលពិឃាត ១៩៧៥-១៩៧៩ ហើយបណ្តោយអោយប្រទេសយួនយកលេសឈ្លានពាន និង ដាក់អណានិគមន៍លើកម្ពុជាមុនការប្រុងចូលអន្តរគមន៍អន្តរជាតិ តែសហគមន៍អន្តរជាតិបានឆ្លើយតបវិញដោយការដាក់គំនាបសេដ្ឋកិច្ចនិងការទូតយ៉ាងធ្ងន់ធ្ងរលើប្រទេសយួន រហូតភាគីយួនស្វែងរកការចរចាសន្តិភាពដើម្បីបញ្ចប់ទណ្ឌកម្មរបស់សហគមន៍អន្តជាតិ។ តែគួរអោយសោកស្តាយដែលសហគមន៍អន្តរជាតិបានត្រឹមជួយធ្វើអន្តរាគមន៍អោយមានកិច្ចព្រមព្រៀងទីក្រុងប៉ារីស តែមិនបានតាមដានត្រួតពិនិត្យនិងមានវិធានការសមស្របក្នុងករណីរំលោភបំពាន ធ្វើដូច្នេះហាក់មានចេតនាគ្រាន់តែចង់ទម្លាយការកាំងស្ទះសេដ្ឋកិច្ចនិងការទូតដល់ប្រទេសយួន ហើយបើកផ្លូវអោយប្រទេសយួន និងប្រទេសឯទៀតរំលោភឈ្លានពានកម្ពុជារិតតែធ្ងន់ធ្ងរទៀតក្រោមរូបភាពប្រជាធិបតេយ្យនិងឯករាជ្យក្លែងក្លាយ និងបានកែរប្រែពីអាណានិគមន៍ចំហរមកជាអាណានិគមន៍បែបថ្មី រិតតែសាហាវនិងអមនុស្សធម៌ ដែលប្រជាពលរដ្ឋខ្មែរគ្មានលទ្ធភាពបន្តិចសោះដើម្បីទប់ស្កាត់ ព្រោះកម្លាំងតស៊ូត្រូវគេរំលាយចោល ចង់ចោទប្រកាន់យួនឬចិនបានរំលោភឈ្លានពានខ្លួន ក៏ត្រូវអង្គការសិទ្ធិមនុស្សស្អីទេនោះនៅកម្ពុជាតាមស្រែកគំរាមថាជាការរើសអើងពូជសាសន៍ឬថាជារឿងខ្មែរនិងខ្មែរ។ល។និង។ល។

សរុបសេចក្តីមក កិច្ចព្រមព្រៀងទីក្រុងប៉ារីសបើគ្មានការអនុវត្តន៍ដូចអ្វីដែលបានចែងនិងបានចុះសន្យាដោយប្រទេសទាំង១៨ទេ គឺបានត្រឹមតែជាការជួយសង្គ្រោះដល់ប្រទេសយួន និងបើកផ្លូវអោយប្រទេសនេះនិងប្រទេសខិលខូចមួយចំនួនព្រមទាំងពួកផ្តាច់ការនិងឈ្មួញទិច្ចរិតដ៏ទៃ ទៀតរំលោភឈ្លានពានកម្ពុជានិងពលរដ្ឋខ្មែរក្នុងបរិបទថ្មីមួយ។ បញ្ហាដែលកើតមានឡើងនៅកម្ពុជាដូចដែលលោក Richard Roger បានចោទប្រកាន់រដ្ឋាភិបាលហ៊ុន-សែន ថាបានប្រព្រឹត្តិឧក្រិដ្ឋកម្មប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្ម ប្រឆាំងនឹងមនុស្សជាតិ និងសង្គ្រាមឬការបង្ហូរឈាមដែលនឹងអាចកើតមានឡើងនៅកម្ពុជានិងនៅក្នុងតំបន់ គឺដោយ សារតែការមិនអនុវត្តន៍កិច្ចព្រមព្រៀងទីក្រុងប៉ារីស ហើយវាជាការទទួលខុសត្រូវរបស់សហគមន៍អន្តរជាតិមួយចំណែកយ៉ាងធំ។ បុស្បា